# ដំណាំឈើហូបផ្លែ

រ៉ុន សុផាន់ណារ៉ា

ប្រធានការិយាល័យក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម មន្ទីរកសិកម្ម
ខេត្តបន្ទាយមានជ័យ

# មាតិកា

. សេចក្តីផ្តើម

. ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ

ក. លក្ខណៈទីកន្លែង

ខ. ស្ថានភាពដី

គ. អាកាសធាតុ

ឃ. ទឹក

# មាតិកា

. **ការរៀបចំដីដាំដុះ**

ក. អំពីប្រភេទដី

ខ. រៀបចំគំរោងប្លង់ចំការ

គ. របង

ឃ. រៀបចំប្រពន្ធ័ទឹក

# មាតិកា

. **ការរៀបចំដីដាំដុះ (ត)**

ង. រៀបចំផ្លូវក្នុងចំការ

ច. រៀបចំរង

ឆ. ការភ្ជួររាស់

ជ. រៀបចំរណ្តៅ

# មាតិកា

. **ការរៀបចំដីដាំដុះ (ត)**

ឈ. រៀបចំថ្នាលកូនឈើពូជ

ក. ប្រភពពូជ

ខ. គុណភាពពូជ

គ. សុខភាពពូជ

ឃ. អាយុកាលរបស់កូនឈើ

ង. ប្រភេទឈើសំរាប់ទីផ្សារ

# មាតិកា

. **ការដាំឈើហូបផ្លែ**

ក. ពេលវេលាដាំ

ខ. ការរៀបចំកូនឈើ

គ. ការរៀបចំសំរាប់ដាំ

ឃ. របៀបដាំកូនឈើ

# មាតិកា

. **ការដាក់ជី**

. **ការបំបែកពូជ (ពង្រីកពូជ)**

- ការបណ្ដុះកូនដោយគ្រាប់
- ការសាកមែក
- ការបំបៅ

# មាតិកា

**ការបំបែកពូជ (ពង្រីកពូជ) (ត)**

- ការភ្ជាប់ភ្នែក
- ការតត្រួយ
- ការបំបែកពូជដោយកូនដំណាំ
- ការផ្សាំ

# មាតិកា

. ការកាត់តាក់តែងមែក

. ការប្រមូលផល

# សេចក្តីផ្តើម

. ជារុក្ខជាតិដែលមានសារៈសំខាន់
សំរាប់ជីវិតមនុស្ស និងសត្វ

. មានជីវជាតិ និង វីតាមីនខ្ពស់
សំរាប់ទ្រទ្រង់រាងកាយ

. ជាឱសថ

. អុសដុត



# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ

## ក.លក្ខណៈទីកន្លែង

- ត្រូវរកកន្លែងជិតផ្លូវចេញចូល
- កន្លែងដែលមានប្រភពទឹកដូចជា ស្រះ អាង ប្រឡាយ ស្ទឹង
- កន្លែងសមស្របតាមប្រភេទឈើដែលគេដាំ





# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

## ក.លក្ខណៈទីកន្លែង (ត)

- កន្លែងជិតទីផ្សារ និងតំរូវការទីផ្សារផង
- ត្រូវយល់ដឹងអោយបានច្បាស់ ពីបរិស្ថានសមស្របតាមប្រភេទឈើដែលត្រូវយកមកដាំ
- ត្រូវនៅជិតកន្លែងដែលមានសិប្បកម្ម ឬរោងចក្រសំរាប់កែច្នៃផ្លែឈើ ។

# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

## ខ.ស្ថានភាពដី

- **ដីខ្ពង់រាបៈ** ដីខ្ពស់ដែលមិនធ្លាប់មានលិចទឹក ស្រស់ទឹក មិនជាំទឹកផង ដីខ្ពស់របៀបនេះមិនចាំបាច់លើករងទេ
- បើដីខ្ពស់មានស្មៅ ឬព្រៃស្ដុកស្ដុបទ្រុប យើងត្រូវកាប់ឆ្ការ កាត់ឬប្រើថ្នាំសំលាប់កំចាត់ជាមុន ។

# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

**ខ.ស្ថានភាពដី (ត)**

- **ដីវាលរាបៈ** គឺជាដីទាបដែលធ្លាប់លិចទឹក ទឹកជំនន់ក្នុងពេលខ្លះ
  - ដីប្រភេទនេះភាគច្រើនជាដីឥដ្ឋ ហើយជាំទឹកផង ។
  - គប្បីលើករងអោយបានខ្ពស់ផុតពីទឹកជំនន់ និងធ្វើភ្លឺខ្ពស់ការពារទឹកជំនន់ ។
  - មានការងារធ្វើច្រើន និងចំណាយទុនច្រើនក្នុងការដាំឈើហូបផ្លែ ។

# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

## ខ.ស្ថានភាពដី (ត)

- ដីចំរាក់ភ្នំៈ ជាដីខ្ពស់ហើយចោត មានជំរាលច្រើនជាង ១0%
- គប្បីលើកដីអោយបានខ្ពស់ជាថ្នាក់ៗ
- គឺត្រូវចំណាយទុន ច្រើនក្នុងការដាំឈើហូបផ្លែ។

# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

**គ.អាកាសធាតុ**

- ដំណាំឈើហូបផ្លែត្រូវការទាក់ទងទៅនឹង

  - របបទឹកភ្លៀង
  - សីតុណ្ហភាព
  - សំណើម
  - ពន្លឺអោយបានសមស្រប តាមប្រភេទពូជឈើហូបផ្លែ

# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

## ឃ.ទឹក

- រុក្ខជាតិគ្រប់ប្រភេទត្រូវការទឹកចាំបាច់ដើម្បីលូតលាស់បាន
- ចំការឈើហូបផ្លែត្រូវនៅជិតប្រភពទឹក ដូចជា ស្រះ ទន្លេ ស្ទឹង ប្រឡាយ
- ជីកជាអណ្តូង ឬស្រះធំតូចដើម្បីស្តុកទឹកសំរាប់ធ្វើការស្រោចស្រពឈើហូបផ្លែនៅពេលអស់ទឹកភ្លៀង។

# ការជ្រើសរើសទីកន្លែងសំរាប់ដាំឈើហូបផ្លែ (ត)

**ឃ.ទឹក (ត)**

- រុក្ខជាតិគ្រប់ប្រភេទត្រូវការទឹកចាំបាច់ដើម្បីលូតលាស់បាន
- គប្បីមានប្រឡាយបង្ហូរទឹកចេញពីចំការ ជៀសវាងការជោគជាំទឹក

# ការរៀបចំដីដាំដុះ

**ក.រៀបចំគំរោងប្លង់ចំការ**

- ត្រូវតែគិតគូច្បាស់អំពីទីតាំងទាំងឡាយនៅក្នុងចំការដូចជា ស្រះ រោងជី រោងបណ្តុះកូនឈើ ប្រពន្ធ័ស្រោចស្រព និងផ្លូវចេញចូលអោយបានត្រឹមត្រូវ ។ល ។
- ប្រពន្ធ័ដាំដុះ ដូចជា រណ្តៅ ចន្លោះរណ្តៅ ជួររណ្តៅ និងគំលាតកន្លែងដាំតាមប្រភេទឈើនិមួយៗ ។



# ការរៀបចំដីដាំដុះ (ត)

**ខ.របង**

- ធ្វើរបងអោយគត់ម៉ត់ល្អ ជៀសវាងសត្វគ្រប់ប្រភេទចូល ទៅបំផ្លាញដំណាំ
- របងនេះយើងអាចធ្វើដោយ បង្គោល ឬរបងស្រស់ដោយពទ័បន្លាលួសជុំវិញអោយបានត្រឹមត្រូវ ។

# ការរៀបចំដីដាំដុះ (ត)

## គ.រៀបចំប្រព័ន្ធទឹក

- រៀបចំតាមប្រឡាយបង្ហូរ
- រៀបចំម៉ាស៊ីនបង្ហូរតាមទុយោ
- រៀបចំតាមប្រពន្ធ័ទឹកវិល



# ការរៀបចំដីដាំដុះ (ត)

**ឃ.រៀបចំផ្លូវក្នុងចំការ**

- ងាយស្រួលដឹកសំភារៈចេញចូល

**ង.រៀបចំរង**

- ដីវាលរាបៈ ត្រូវតែជីកប្រឡាយ ផ្ដុំដីបានជារងខ្ពស់ផុតទឹកលិច។
- ដីខ្ពង់រាបៈ មិនចាំបាច់លើករងទេ គ្រាន់តែរៀបចំប្រពន្ធ័រណ្ដៅដាំជាការស្រេច។

# ការរៀបចំដីដាំដុះ (ត)

**ច.ការភ្ជួររាស់**

- មុននឹងធ្វើការដាំដុះចាំបាច់ ត្រូវតែភ្ជួររាស់ដីអោយបានជ្រៅច្រើនដង រាស់អោយបានល្អិត និងកៀរអោយស្មើផង ចំពោះចំការលើករងថ្មីវិញមិនចាំបាច់ភ្ជួររាស់ឡើយ ។

**ឆ.ការរៀបចំរណ្តៅ**

ខ្នាតធំ ១ម x ១ម x ១ម

ខ្នាតមធ្យម 0.៧៥ម x 0.៧៥ម x 0៧៥ម

ខ្នាតតូច 0.៥ម x 0.៥ម x 0.៥ម

# ការរៀបចំដីដាំដុះ (ត)



ការត្រៀមរណ្តៅ
សំរាប់ដំណាំឈើ ហូបផ្លែ
ដីស្រទាប់លើ
ដីស្រទាប់ក្រោម
30 សម
100 សម
រណ្តៅ
70 សម
100 សម
កំពស់ 25 សម
កំពស់ 25 សម
10 សម
10 សម
កំពស់ 25 សម
រណ្តៅ

# ការរៀបចំដីដាំដុះ (ត)

**ដ.ការរៀបចំថ្នាលកូនឈើ**

ទំហំ ៨ម x ១០ម ឬតាមលទ្ធភាព

ត្រូវយកស្លឹកដូង ឬសំណាញ់ពណ៌ខ្មៅមកគ្របពីលើ និងបាំងពីខាងដើម្បីជាម្លប់ដល់កូនឈើដែលយកមកបណ្តុះ ឬផ្សាំ។

ក្នុងរោងមានកន្លែងសំរាប់បណ្តុះ និងផ្សាំកូនឈើ មុនយកទៅដាំក្នុងចំការថ្នាលបណ្តុះអាចធ្វើជារបាំងដែលមានកំពស់ 0.៥0ម៉ែត្រ និងទទឹង ១ម៉ែត្រ និងបណ្តោយតាមលទ្ធភាព សំរាប់បណ្តុះកូនឈើ។ យកឈើនីវធ្វើជារបាំងសំរាប់ផ្អែកកូនឈើផ្សាំ

# ពូជ

. **ពូជជាកត្តាមួយក្នុងចំណោមកត្តាដទៃទៀតដែលកំនត់ទិន្នផលឈើហូបផ្លែ**

- ប្រភពពូជ
- គុណភាពពូជ
- សុខភាពពូជ
- អាយុកាលរបស់កូនឈើ
- ប្រភេទឈើសំរាប់ទីផ្សារ

# ការដាំឈើហូបផ្លែ

**ការដាំដើមឈើហូបផ្លែមាន៥ចំនុចសំខាន់ៗ :**

- ពេលវេលាដាំ
- ការរៀបចំកូនឈើ
- ការរៀបចំសំរាប់ដាំ
- របៀបដាំកូនឈើ
- ការគ្រប់គ្រងធាតុអាហារចិញ្ចឹម (ការប្រើប្រាស់ជី)

# ការដាក់ជី

- គឺជាកត្តាចាំបាច់បំផុតសំរាប់បង្កើនទិន្នផល
- ការប្រើប្រាស់ជីទៅលើវាធ្វើអោយផ្លែមលុ្អសំបករលោងស្អាត រសជាតិឆ្ងាញ់
- ការដាក់ជីក្នុងចំការត្រូវនៅឆ្ងាយពីគល់ តាមទំរង់ស្លឹកដោយកាប់ដីបំផុស ជុំវិញឈើរួចយកជី ១៥-១៥-១៥ លាយជាមួយ ជីកំប៉ុស្ដិ៍ដាក់ក្នុងស្នាមកាប់បំផុស (តាមអាយុកាល និងកំរិត) រួចយកចំបើង ឬស្មៅគ្របពីលើ និងស្រោចទឹក ។
- ការដាក់ជីគឺធ្វើឡើង ៣ដង ក្នុងមួយឆ្នាំ

# ការដាក់ជី (ត)

- លើកទី១ : ក្រោយពេលប្រមូលផលរួច ១-២ អាទិត្យ យើងធ្វើការតាក់តែងមែក និងដាក់ជីអ៊ុយរ៉េបន្ថែម 0.៣គីឡូក្រាម/ដើម ។
- លើកទី២ : ពេលដែលដើមឈើចាប់ផ្តើមចេញផ្កា ដាក់ជីផូស្វាត 0.៣ គីឡូក្រាម/ដើម ។
- លើកទី៣ : ពេលរុក្ខជាតិចាប់ផ្តើមក្តិបប៉ុនមេដៃ ជីប៉ូតាស្យូមក្លរ៉ួ 0.៣ គីឡូក្រាម/ដើម ។

# ការដាក់ជី (ត)





# ការពង្រីកពូជ

. ការបណ្ដុះកូនដោយគ្រាប់ទៀប ខ្នុរ ស្វាយចន្ទី ម្កាក់ ក្រខុប ក្រសាំង ចាន់ ប៉ែន





# ការពង្រីកពូជ (ត)

- ការសាកមែក ក្រូច សាវម៉ាវ គូលេន មៀន ត្របែក ជំពូរ ទទឹម ទំពាំងបាយជូរ ភ្លៀវ លុត ។ល ។
- មែកមានអាយុ ៦ខែ ទៅ មួយឆ្នាំ
- មែកបញ្ឈរ ឬទ្រេត (មិនសូវទ្រេតជាង ៩០ ដឺក្រេទេ)
- មែកដែលមានស្លឹកទាំងអស់បានទទួលពន្លឺថ្ងៃគ្រប់គ្រាន់
- មែកគ្មានរោគ មែកគ្មានផ្អែកងាប់
- មែកកំពុងមានការលូតលាស់

# ការពង្រីកពូជ (ត)

- ការសាកមែក





# ការពង្រីកពូជ (ត)

- ការបំបៅ



# ការពន្លឺកពូជ (ត)

- ការតមែក: ស្វាយ ខ្នុរ ពុទ្រា កំពីងរាជ ភ្លៀវ អំពិលផ្អែម
- ការជ្រើសរើសកូនធ្វើជាដើមគល់: ដកយកកូនណាដែលល្អ លាងទឹកអោយស្អាត កាត់ឬសអោយបានសមរម្យ ត្រាំទឹកសំលាប់មេរោគផ្សិត (Fundozol) ចំនួន ១៥នាទី ក្នុងមួយស្លាបព្រាបាយលាយទឹកមួយលីត្រ ប្រើអ័រមូន Seradix យកមកលាយទឹកខាប់ៗ រួចច្របល់ចូលក្នុងទឹកថ្នាំនេះអោយបានរយៈពេល ៥-១០នាទី ។

# ការពង្រីកពូជ (ត)

- ការតមែក:

  - ជ្រើសរើសមែកពូជ

  - មែកកំពុងមានការលូតលាស់

  - មែកទទួលពន្លឺថ្ងៃបានល្អ

  - មែកមានអាយុ ៤-៦ខែ

  - មែកមានមុំមិនលើសពី ៩០ អង្សា

# ការពង្រីកពូជ (ត)

- ការភ្ជាប់ភ្នែក
- ស្វាយ ខ្នុរ ក្រូច

- ភ្នែកមានរាងពកៗ
- ភ្នែកត្រៀមចេញត្រួយ
- ភ្នែកមានរាងដូចឬស

# ការពង្រីកពូជ (ត)

- ការតម្រួយ

  ការតម្រួយបែបសៀតចំហៀង

  ការតម្រួយបែបអក្សរ វ៉េ



# ការពង្រីកពូជ (ត)

- ការបំបែកពូជដោយកូនដំណាំៈ ចេក ម្នាស់
- ការបំបែកពូជដោយផ្លែៈ ដូង ស្លា ត្នោត



# ការកាត់តាក់តែងមែក

- មែកត្រូវកាត់ចោល

  - មែកអំពង់

  - មែកនៅក្រៅបរិវេណគល់

  - មែករំហែកបាក់ងាប់

  - មែកដែលត្រូវបំផ្លាញដោយរោគ និងសត្វល្អិតមិនអាចរក្សាអោយបានដូចដើម

# ការកាត់តាក់តែងមែក (ត)

- គោលបំណង

កាត់តែងមែកដើម្បីយកគ្រោងរាងដើម

ការកាត់តែងមែកស្វាយដើម្បីអោយស្រួលធ្វើការ

កាត់តែងមែកដើម្បីអោយដើមឈើចេញផ្កាព្រមគ្នា

កាត់តែងដើម្បីអោយដើម និងផ្លែមានគុណភាពល្អ

កាត់តែងដើម្បីអោយដើមឈើផ្លែភ្ញាក់ខ្លួនឡើងវិញ

# ការកាត់តាក់តែងមែក (ត)







# ការកាត់តាក់តែងមែក (ត)





# ការប្រមូលផល

- មុនយើងចាប់ផ្តើមប្រមូលផល យើងត្រូវត្រៀមរទេះ កញ្ជោរ កេស កន្ទ្រៃ កាំបិត ជណ្តើរ ។
- ផ្លែឈើដែលបេះហើយត្រូវរៀបចំដាក់ក្នុងកេស ដោយចន្លោះផ្លែនីមួយៗ ត្រូវខណ្ឌដោយស្លឹកឈើ ឬស្មៅ ដើម្បីជៀសវាងការកកិតគ្នារវាងផ្លែ និងផ្លែនាំអោយខូចគុណភាពផ្លែឈើ ។
- ត្រូវតំរៀបតាមប្រភេទ ផ្លែធំ តាមធំ តូចតាមតូច

# ការប្រមូលផល (ត)







# សូមថ្លែងអំណរគុណ

## ចំពោះការយកចិត្តទុកដាក់ស្តាប់